ការរំឭកអំពីធនធានសម្រាប់ក្រុមគ្រួសារ សុវត្ថិភាព និងការរៀននៅសាលា

ក្រសួងអប់រំឡុងប៊ីច កំពុងតាមដានយ៉ាងជិតដល់លើការកើនឡើងនូវករណីកូវីឌ-១៩នៅក្នុងក្រុង តំបន់ និងប្រទេសទាំងមូល។ នៅពេលនេះ ក្រសួងអប់រំបន្តផ្តល់ធនធានសំខាន់ៗសម្រាប់ក្រុមគ្រួសារ ព្រមទាំងការរំឭកខ្លះៗអំពីសុវត្ថិភាពនិងការទៅរៀននៅសាលា។

សិស្សនិងក្រុមគ្រួសារត្រូវបានលើកទឹកចិត្តឱ្យធ្វើទំនាក់ទំនងបើពួកគាត់ត្រូវការជំនួយ រួមទាំងការបញ្ជូនសម្រាប់ទទួលធនធានផ្សេងៗក្នុងសហគមន៍។ មជ្ឈៈមណ្ឌលធនធានគ្រួសារ Family Resource Centers និងក្រុមយុវជនស្នាក់នៅកន្លែងគេទទួលចិញ្ចឹម នៅបន្តផ្តល់សេវាកម្មដល់សិស្សនិងក្រុមគ្រួសារ។ នាយកដ្ឋាន Parent University បន្តបង្កើតកម្មវិធីនិងធនធានផ្សេងៗសម្រាប់មាតាបិតា។ ដើម្បីឱ្យបានដឹងថែម សូមចូលទៅ lbschools.net ឬដោយទាក់ទងសាលារៀនរបស់កូនអ្នក។

សូមចងចាំទុកនូវរបៀបរក្សាសុវត្ថិភាពខាងក្រោមនេះពេលនៅផ្ទះនិងពេលទៅសាលារៀន ដូចជាការទៅសួរនាំជំនួយពីបច្ចេកទេសឬទៅទទួលអាហារជាដើមៈ

- មុននឹងបំរុងមកសាលារៀន សូមសួរខ្លួនឯងមុនសិនថា “ តើខ្ញុំនិងជាប់សំណួរពិនិត្យសុខភាពដោយស្មោះត្រង់ដែរឬទេ រួមទាំងសំណួរថាតើខ្ញុំមានរោគសញ្ញាកូវិឌដែរឬអត់?” បើចម្លើយគឺ “ ទេ” សូមសម្រេចនៅផ្ទះ តាមដានមើលរោគសញ្ញារបស់អ្នក ហើយគិតគូទៅធ្វើតេស្តកូវិឌ។
- បើអ្នកធ្វើតេស្តវិជ្ជមានកូវិឌ១៩ សម្រាប់មូលហេតុណាមួយក៏ដោយ (រួមទាំងតេស្តបង្ការ ការចង់ដឹង ឬការត្រូវសម្រាប់ការធ្វើដំណើរ) សូមកុំមកសាលារៀនរហូតទាល់តែអ្នកបានទទួលលទ្ធផលតេស្តដែលបញ្ជាក់ថាអ្នកពុំមានវីរុសកូវិឌទេ។
- ការពាក់ម៉ាសគឺចាំបាច់សម្រាប់ការធ្វើចលនានៅសាលារៀននិងនៅក្នុងអគាររបស់ក្រសួងអប់រំយើង។
- ចៀសវាងចែករំលែកអាហារជាមួយមនុស្សក្រៅពីសមាជិកក្នុងគ្រួសាររបស់អ្នក។ ការនៅជិតមនុស្ស ការមិនពាក់ម៉ាស (នៅពេលទទួលទាន) បានបង្ហាញជាភស្តុតាងថាជាហានិភ័យខ្ពស់ក្នុងការចម្លងវីរុស។
- ចៀសវាងរៀបចំគ្រោងឬចូលរួមក្នុងពីធីជួបជុំអបអរពេលបុណ្យទាននៅក្រៅពីផ្ទះរបស់អ្នក។

ក្រសួងអប់រំនៅតែគ្រោងបើកជាគន្លាក់ៗឱ្យសិស្សទៅរៀននៅសាលាវិញនៅពេលណាដែលអាចធ្វើទៅបានដោយសុវត្ថិភាព។ សម្រាប់បច្ចុប្បន្ននេះ LBUSD នឹងបន្តធ្វើគ្រប់បែបយ៉ាងដែលអនុញ្ញាតឱ្យ នៅក្នុងស្ថានភាពបច្ចុប្បន្ន និងការណែនាំបញ្ជារពីក្រសួងសុខាភិបាលក្នុងតំបន់។ ការស្ទង់ប៉ាន់មើលសមត្ថភាពសិស្សផ្ទាល់ នៅសាលារៀនដែលមានកំរិត នឹងបន្តធ្វើទៅ ព្រមទាំងការទទួលមើលថែកុមារនិងការហាត់ប្រាណកីឡាផងដែរ។ គម្រោងឱ្យសិស្សទៅរៀននៅសាលាវិញជាគន្លាក់ៗ នឹងចាប់ផ្តើមធ្វើនៅពេលសកម្មភាពថែមទៀតបានទទួលការអនុញ្ញាត។

សូមរងចាំមើលព័ត៌មានបច្ចុប្បន្នភាពថែមទៀតមុនពេលសម្រាករដូវរងា។